ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**កំពង់ផែស្វយ័តក្រុងព្រះសីហនុ**

ថ្ងៃព្រហស្បតិ៍ ៨រោច ខែបឋមសាឍ ឆ្នាំច សំរឹទ្ធិស័ក ២៥៦២
ខេត្តព្រះសីហនុ, ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៨

# សេចក្តីជូនដំណឹង

## ស្តីពីការបែងចែកភាគលាភរបស់ កសស ប្រចាំឆ្នាំ២០១៧

**កំពង់ផែស្វយ័តក្រុងព្រះសីហនុ** (កសស) មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតប្រភេទ "គ" របស់ **កសស** ឲ្យបានជ្រាបថា យោងតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាលក្នុងកិច្ចប្រជុំវិសាមញ្ញលើកទ១ី អាណត្តិទី៧ នាថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៨ **កសស** បានសម្រេចបែងចែកភាគលាភប្រចាំឆ្នាំ២០១៧ ជូនភាគហ៊ុនិក ដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតប្រភេទ "គ" ដូចខាងក្រោម៖

១. ប្រភេទភាគលាភដែលត្រូវបែងចែក (Type of Dividend) : សាច់ប្រាក់

២. រយៈពេលភាគលាភ (Period of Dividend) : ប្រចាំឆ្នាំ២០១៧

៣. អនុបាតនៃការបែងចែកភាគលាភ (Dividend Payout Ratio) : ៣៤,៣៧%

៤. ភាគលាភសរុបដែលត្រូវបែងចែក (Total Dividend) : ៨.៦៤១.៥២៥.៧៧៦ រៀល

៥. ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (Dividend per Share) : ៤០៣ រៀល

៦. កាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគហ៊ុនិក ដែលត្រូវទទួលបានភាគលាភ(Record Date):

**ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៨**

៧. កាលបរិច្ឆេទចាប់ផ្តើមទូទាត់ភាគលាភ (Payment Date) :**ថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៨**

បញ្ជាក់៖

- ភាគហ៊ុនិកដែលធ្វើការលក់មូលបត្រកម្មសិទ្ធិរបស់ខ្លួន នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៨ នៅតែមានសិទ្ធិទទួលបានភាគលាភដដែល។
- ភាគហ៊ុនិកដែលធ្វើការទិញមូលបត្រកម្មសិទ្ធិ នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៨ នឹងមិនមានសិទ្ធិទទួលបានភាគលាភទេ។


តិរវិថី សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
Tarak Vithei Samdech Akka Moha Sena Padei Techo HUN SEN
Sangkat N°3, Preah Sihanouk City, Preah Sihanouk Province
Office : 034 933 416; 034 933 511 Pilot : 034 933 507; Fax : 034 933 693
E-mail : pasinfo@pas.gov.kh; spsez@pas.gov.kh
Website: www.pas.gov.kh

- ការទូទាត់ភាគលាភជូនភាគហ៊ុនិកដែលត្រូវទទួលបានភាគលាភ នឹងចាប់ផ្តើមពីថ្ងៃទី**០១ ខែសីហា ឆ្នាំ២០១៨ ដល់ ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៨** នៅរៀងរាល់ថ្ងៃធ្វើការ។ យោងតាមគោលការណ៍ណែនាំស្តីពីការបែងចែកភាគលាភលេខ **១៦៣ គ.ម.ក/គ.ណ.ន** ចុះថ្ងៃទី ២៦ ខែមីនា ឆ្នាំ២០១៤ ដែលកំណត់ពេលវេលានៃការបែងចែកភាគលាភយ៉ាងយូរ៧ ថ្ងៃបន្ទាប់ពីថ្ងៃប្រកាសបញ្ជីឈ្មោះភាគហ៊ុនិកដែលត្រូវទទួលភាគលាភ ប៉ុន្តែ ដោយ **កសស** ទើបតែធ្វើការបែងចែកភាគលាភលើកទី១ **កសស** ពន្យារពេលពីរថ្ងៃនៃថ្ងៃធ្វើការដើម្បីរៀបចំឯកសារផ្សេងៗ ។ កសស នឹងធ្វើការទូទាត់ភាគលាភជូនភាគហ៊ុនិកតាមកាលបរិច្ឆេទកំណត់ខាងលើ គឺ**ថ្ងៃទី១ ខែសីហា ឆ្នាំ២០១៨** ។

- ភាគហ៊ុនិកអាចធ្វើការតវ៉ាលើការទូទាត់ភាគលាភចាប់ពី**ថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៨ ដល់ ថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៨**។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់របស់ **កសស** ដូចខាងក្រោម៖

-ឈ្មោះ: **ធនាគារ អេស៊ីលីដា ភីអិលស៊ី**

-អាសយដ្ឋាន: ជាន់ទី៥ អគារលេខ៦១ មហាវិថីព្រះនរោត្តម សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ

-ទូរសព្ទ: +៨៥៥ (0) ២៣ ៩៩៨ ៧៧៧ (Ext :០៥០១៣)

-ទូរសារ: +៨៥៥ (0) ២៣ ៩៩៨ ៦៦៦

-ទូរសព្ទដៃ: +៨៥៥ (0) ១៥ ៦០០ ៧៤៣

-សារអេឡិចត្រូនិក: lim.an@acledabank.com.kh

**កំពង់ផែស្វយ័តក្រុងព្រះសីហនុ**

PORT AUTONOME DE SIHANOUKVILLE